**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ១៨៧ ព.ណ.គនព.ប្រក

# ប្រកាស
## ស្តីពី
## ការកំណត់លក្ខខណ្ឌតម្រូវហាឡាលកម្ពុជា សម្រាប់សត្តឃាតដ្ឋាន

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/៦១ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការតែងតាំងលោក ឧកញ៉ា សុះ កំរី ជាចាងហ្វាងនៃគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០១ ស្តីពីការកែសម្រួល និងបំពេញបន្ថែមអនុក្រឹត្យលេខ ៥ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង សម្របសម្រួលការត្រួតពិនិត្យគុណភាព សុវត្ថិភាព ផលិតផល និងសេវាកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៦០ អនក្រ.បក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ ១២២ សសរ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា
- យោងប្រកាសលេខ ៣២៩ ពណ.ប្រក.គនព ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការបង្កើតលេខាធិការដ្ឋាននៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាសកម្ពុជា
- យោងប្រកាសលេខ ៣៥៨ ពណ.ប្រក.គនព ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ស្តីពីការបង្កើតក្រុមឯកទេសផលិតផលហាឡាលកម្ពុជា
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម ។



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

# សម្រេច

**ប្រការ ១**.-

ត្រូវបានកំណត់ លក្ខខណ្ឌតម្រូវហាឡាលកម្ពុជា សម្រាប់សត្តឃាតដ្ឋាន។

**ប្រការ ២**.-

**និយមន័យ**

- ហាឡាល ឬ HALAL ឬ حلال (ជាភាសាអារ៉ាប់) សំដៅដល់វត្ថុណាមួយ ឬសេវាកម្មណាមួយ ដែលអនុញ្ញាតឲ្យប្រើប្រាស់ ឬឲ្យចូលរួមដោយអាស្រ័យទៅតាមច្បាប់ឥស្លាម។ ពាក្យនេះត្រូវបានប្រើជាទូទៅទាក់ទងនឹងផលិតផលម្ហូបអាហារ ផលិតផលសាច់ គ្រឿងសម្អាង ផលិតផលថែរក្សាខ្លួន ឱសថ អាហារបំប៉ន គ្រឿងផ្សំ ម្ហូបអាហារ និងសម្ភារប្រើប្រាស់ផ្សេងៗទៀត
- ហារ៉ាម (ហារ៉ាំ) ឬ HARAM ឬ حرام (ជាភាសាអារ៉ាប់) មានន័យថា (បម្រាមដាច់ខាត) វត្ថុ ឬសកម្មភាពដែលច្បាប់ឥស្លាមបានហាមឃាត់ ឬអ្វីដែលផ្ទុយនឹងហាឡាល
- ច្បាប់ឥស្លាម ឬ SARI AT ISLAM ឬ الشريعة الإسلامية (ជាភាសាអារ៉ាប់) សំដៅដល់ច្បាប់ដែលជនមុស្លីមត្រូវអនុវត្តតាមដោយផ្អែកលើគម្ពីរអាល់គួរអាន ស៊ុណ្ណះ អ៊ីជ្មាក និងគីយ៉ាស ដែលទទួលស្គាល់ដោយនិកាយហាណាហ្វី ម៉ាលីគី ស្ហាហ្វីអ៊ី ហាំបាលី
- ណាជីស ឬ NAJIS ឬ نجس (ជាភាសាអារ៉ាប់) មានន័យថាកខ្វក់ ភាពស្មោគគ្រោកដោយផ្ទុយនឹងហាឡាល ដែលចាំបាច់ត្រូវតែលាងសម្អាតទើបទៅជាហាឡាល។

**ប្រការ ៣**.-

**ប្រភេទសត្វដែលមិនហាឡាល (ហារ៉ាម ឬ ហារ៉ាំ)**

ក. ប្រភេទសត្វដែលមិនហាឡាលៈ

១. សត្វចតុប្បាទដែលមានចង្កូម ខ្នាយ ក្រញ៉ាំជើង ហើយស៊ីសាច់ជាអាហារ ដូចជា សត្វតោ សត្វខ្លា សត្វឆ្មា សត្វចចក សត្វខ្លាឃ្មុំ ។ល។

២. សត្វស្លាបដែលមានក្រញ៉ាំជើង ចំពុះកោងមុតស្រួច ចុះឆាបចាប់ចំណីដោយក្រញ៉ាំជើងជាអាហារ ដូចជា សត្វឥន្ទ្រី សត្វត្មាត សត្វក្អែក សត្វសេក ។ល។

៣. ប្រភេទសត្វល្អិតគ្រប់ប្រភេទ ដែលមានស្លាប ឬគ្មានស្លាប មានជើងតិចឬច្រើនរស់នៅលើចុងឈើ ឬក្នុងដី ឬលើដី ដូចជា សត្វអាពីង សត្វពីងពាង ។ល។

៤. ប្រភេទសត្វមានពិសដូចជា សត្វពស់ សត្វខ្ទួយ សត្វក្ដែប។ល។

៥. ចំពោះសត្វរស់នៅបានពីរ (០២) កន្លែង ក្នុងទឹក និងលើគោកដូចជា សត្វហ៊ីង សត្វគីង្គក់ សត្វអណ្តើក សត្វក្រពើ ។ល។

៦. ប្រភេទសត្វកាយរូង សូម្បីសត្វស្លាប ឬសត្វជើងបួន ឬ សត្វល្មូន ដូចជា សត្វកណ្ដុរ សត្វជៀស សត្វត្រកួត សត្វសំពោច សត្វកំប្រុក សត្វស្កា ។ល។

៧. សត្វដែលរស់នៅក្នុងទឹក ដែលមានជាតិពុល ដូចជា ត្រីកំពត សត្វហ៊ីង និងសត្វល្អិតមួយចំនួនទៀត

៨. សត្វដែលមិនអនុញ្ញាតឲ្យសម្លាប់ដូចជា សត្វស្រមោច សត្វឃ្មុំ និងសត្វត្រសេះ ។ល។

៩. សត្វស្លាប់ដោយខ្លួនឯងដោយមិនសំឡេះ ឬសត្វដែលបានសំឡេះតែមិនធ្វើតាមច្បាប់សាសនាឥស្លាម

១០. សត្វដែលគេធ្វើឲ្យថប់ដង្ហើម ឬមួយត្រូវបានគេវាយឲ្យស្លាប់ ឬស្លាប់ដោយគ្រោះថ្នាក់ផ្សេងៗ

១១. សត្វដែលសំឡេះដោយឥស្លាម តែប្រើសម្រាប់តែដើម្បីបន់ស្រន់ ឬសែនព្រេនអ្វីម៉្យាង។

ខ. ផលិតផលវត្ថុធាតុដើម ឬគ្រឿងផ្សំដែលផលិតចេញពីពពួកសត្វ ឬរុក្ខជាតិខាងក្រោម ត្រូវចាត់ទុកថា ហារ៉ាម (ហារ៉ាំ) ដូចជា៖

១. សត្វជ្រូក សត្វឆ្កែ ឬសត្វដែលជាកូនកាត់របស់សត្វទាំងពីរនេះ

២. ប្រភេទសត្វដែលដើរជើងពីរក៏បាន ឬជើងបួនក៏បាន ដែលប្រើចង្កូម ដូចជា សត្វស្វា សត្វខ្លាឃ្មុំ

៣. សត្វចតុប្បាទទាំងអស់ដែលប្រើចង្កូមរបស់វា ដូចជាសត្វតោ សត្វខ្លា។ល។

៤. សត្វស្លាបទាំងអស់ដែលវាចាប់ចំណីនឹងក្រញាំរបស់វាដូចជា សត្វឥន្ទ្រី សត្វទីទុយ សត្វស្ទាំង សត្វខ្លែង ។ល។

៥. សត្វល្អិតដែលបង្កគ្រោះថ្នាក់ ដូចជា សត្វខ្យាដំរី សត្វខ្ទួយ សត្វក្អែប។ល។

៦. សត្វល្អិតដែលមានក្លិនមិនល្អ ដូចជា សត្វស្រមោច សត្វចៃ សត្វចៃឆ្កែ សត្វសង្អើច សត្វដង្កូវ ឬសត្វរស់នៅក្នុងដី ដូចជា សត្វជន្លេន សត្វដង្កូវដួង ។ល។

៧. សត្វរស់នៅលើគោកក៏បាន ក្នុងទឹកក៏បាន ដូចជាសត្វកង្កែប សត្វគីង្គក់ សត្វហ៊ីង សត្វអណ្តើក សត្វក្រពើ សត្វក្រពា សត្វកន្ធាយ

៨. ប្រភេទសត្វដែលផ្តល់ប្រយោជន៍ដល់មនុស្សដូចជា សត្វលា សត្វសេះ សត្វដំរី

៩. ប្រភេទសត្វល្មូនដូចជា សត្វពស់ សត្វបង្កួយ។ល។

១០. សត្វដែលសាច់របស់វា អាចបង្កគ្រោះថ្នាក់ ជាជាតិពុលជាដើម

១១. សត្វហាឡាលដែលមិនត្រូវបានសំឡេះតាមច្បាប់សាសនាឥស្លាម

១២. ឈាម គ្រប់ប្រភេទ

១៣. អាហារដែលចេញពីរុក្ខជាតិមានជាតិពុល

១៤. អាហារ និងភេសជ្ជៈដែលបង្កឲ្យមានជាតិពុល

១៥. ទឹក ភេសជ្ជៈ និងសារធាតុគីមីទាំងអស់ដែលមានជាតិពុល ឬធ្វើឲ្យស្រវឹង នាំឲ្យគ្រោះថ្នាក់ ឬអាហារ និងភេសជ្ជៈដែលចេញពីសត្វដែលឥស្លាមហាមឃាត់។

១៦. សត្វផ្សេងៗដូចជា សត្វលា សត្វសេះ សត្វដំរី។ល។

**ប្រការ ៤.-**

**ប្រភេទសត្វដែលហាឡាល**

- ប្រភេទ សត្វខ្យង គ្រំ គ្រែង ងាវ ដែលរស់នៅក្នុងទឹក
- សត្វរស់នៅក្នុងទឹកសុទ្ធសាធគ្រប់ប្រភេទ ជាសត្វហាឡាលដែលមិនត្រូវការសំឡេះ លើកលែងលាមក និងឈាម ដែលហូរចេញពីសត្វទាំងនោះ។

**ប្រការ ៥.-**

**ណាជីស ឬ NAJIS ឬ نجس (ភាសាអារ៉ាប់)**

**ក. ប្រភេទណាជីស៖**

១. ណាជីសមូខហ្វហ្វាហ្វះ ឬ NAJIS MUKHAFFAH ឬ ( نجس مخففة ) ដូចជាទឹកនោមក្មេងប្រុសដែលមានអាយុក្រោម ២ឆ្នាំ ដែលមិនទទួលទានអ្វីក្រៅពីទឹកដោះម្តាយ

២. ណាជីសមូតាវ៉ាស្ស៊ីតោះ ឬ NAJIS MUTAWASSITAH ឬ ( نجس متوسطة ) ដែលមានដូចជា ៖

១- ឈាម កម្អួត ទឹកនោម លាមក ទឹករងៃ ខ្ទុះ។ល។ ដែលចេញមកពីសារពាង្គកាយមនុស្ស

២- រាល់វត្ថុរាវដែលនាំឲ្យមានជាតិពុល ដូចជាស្រាបៀរ ជាតិអាល់កុល ទឹកស្រវឹង ទឹកដែលមានសារធាតុពុល នាំឲ្យប៉ះពាល់សុខភាព។ល។

៣- រាល់ប្រភេទទឹកដោះរបស់សត្វដែលមិនហាឡាល

៣. ណាជីសមូហ្គល់ឡាហ្សេះ ឬ NAJIS MUGHLLAZAHឬ ( نجس مغلظة )ដែលមានដូចជា សត្វឆ្កែ សត្វជ្រូក និងកូនកាត់នៃសត្វទាំងពីរនេះ។

**ខ. វត្ថុណាជីសមានដូចជា៖**

១. លាមក ទឹកនោម ឈាម ខ្ទុះ ទឹករងៃ ស្រា អាល់កុល ទឹកស្រវឹង ទឹកពុល សាច់សត្វមិនហាឡាល វត្ថុដែលប្រឡាក់ប្រឡូកនឹងវត្ថុកខ្វក់ទាំងអស់នេះ ឬវត្ថុស្អុយ វត្ថុគួរស្អប់ខ្ពើម។ល។

២. អវយវៈសត្វហាឡាលដែលដាច់ចេញពីខ្លួនវាពេលនៅរស់ ឬ មុនសំឡេះ

៣. បំណែកដាច់ចេញពីសត្វហាឡាលដែលមិនសំឡេះត្រឹមត្រូវ តាមច្បាប់សាសនាឥស្លាម ឬ សត្វដែលស្លាប់ដោយខ្លួនឯង ក្រៅពីសាច់ដូចជា ពោម ធ្មេញ ស្នែង ក្រចក

៤. ឆ្អឹង ស្បែក នៃប្រភេទសត្វហាឡាល ដែលមិនសំឡេះត្រឹមត្រូវ តាមច្បាប់សាសនាឥស្លាម។ ប៉ុន្តែចំពោះស្បែកវិញ សូម្បីជារបស់សត្វហាឡាល ឬហារ៉ាំ ក្រៅពីសត្វជ្រូក និងសត្វឆ្កែ គឺអាចកំណត់ថាហាឡាល បើស្បែកទាំងនោះ ត្រូវបានគេយកទៅកែច្នៃ តាមវិធីសាស្ត្រនៃច្បាប់ឥស្លាម ដែលអាចទុកយូរបាន មិនស្អុយ មិនប្រែប្រួល មិនខូចខាត ក្រោយពីលាងសម្អាតរួចដូចជា  ស្បែកខ្លា ពស់ ក្រពើ។ល។

៥. ចំពោះប្រភេទសត្វមិនហាឡាលដូចជា សត្វឆ្មា សត្វកណ្តុរ សត្វស្វាំង សត្វសេក ។ល។ បើគ្រាន់តែប៉ះពាល់ពួកវាពេលនៅរស់  មិនត្រូវបានហាមឃាត់ទេ  ប៉ុន្តែបំណែកនៃខ្លួនប្រាណរបស់សត្វទាំងនោះដែលដាច់ចេញពីខ្លួន  សូម្បីពេលនៅរស់ឬពេលស្លាប់  គឺមិនហាឡាលទាំងអស់  និងមិនអាចយកមកកែច្នៃធ្វើជាវត្ថុប្រើប្រាស់ ឬធ្វើពាណិជ្ជកម្មបានឡើយដូចជា ភ្លុកដំរី ចង្កូមខ្លា។ល។

៦. រូបចម្លាក់ ជារូបបដិមាករ ជារូបព្រះ ឬជារូបសត្វផ្សេងៗ មិនអាចធ្វើពាណិជ្ជកម្មបានឡើយ លើកលែងតែតុក្កតា សម្រាប់ក្មេងលេងប៉ុណ្ណោះ។

**គ. វិធីសម្អាតណាជីស៖**

១. ដើម្បីសម្អាតណាជីសមូខហ្វហ្វាហ្វះ NAJIS MUKHAFFAH ត្រូវយកណាជីសនោះចេញ ហើយស្រោចទឹកនៅលើកន្លែងនោះ

២. ដើម្បីសម្អាតណាជីសមូតាវ៉ាស៊ីតោះ NAJIS MUTAWASSITAH ត្រូវយកណាជីសនោះចេញ ហើយស្រោចទឹកជម្រះកន្លែងនោះរហូតដល់ពណ៌  និងក្លិនណាជីសនោះត្រូវបាត់បង់  ហើយតម្រូវឲ្យស្រោចជម្រះយ៉ាងតិច ៣ដង

៣. ដើម្បីសម្អាតណាជីសមូហ្គល់ឡាហ្សេះ NAJIS MUGHLLAZAH ត្រូវយកណាជីសនោះចេញ ហើយលាងសម្អាតវាឲ្យបានស្អាតល្អ ក្រោយការសម្អាតស្អាតហើយត្រូវលាងជាមួយទឹក ៧ដង ថែមទៀតក្នុងនោះ១ដង គឺទឹកលាយជាមួយដី ឬទឹកល្អក់។ ដៃជើង ឬឧបករណ៍ គ្រឿងផ្សំ បន្លែ ផ្លែឈើ ។ល។ បើប៉ះពាល់វត្ថុណាជីសខាងលើ ដាច់ខាតត្រូវតែលាងសម្អាតឲ្យបានស្អាតជានិច្ច។  បើមិនស្អាតឡើយ ដោយជូត ឬ ដោយដុតភ្លើង ឬ ដោយចម្អិន ហើយទឹកដែលលាងនោះក៏ត្រូវតែទឹកស្អាតបំផុតដែលមិនទាន់ប្រើប្រាស់    ក្រោយពីស្អាតហើយ    ត្រូវចាក់ទឹកស្អាតប្រោះពីលើដើម្បីឲ្យជាតិមិនស្អាតស្រក់ហូរចុះក្រោម។ ការលាងក្រៅពីទឹកស្អាតដូចជា ទឹកដូង ទឹកតែ ឬទឹកប្រើរួច មានឈ្មោះថាវត្ថុ ឬសាច់បានលាងនោះនៅតែហាជិស្សដដែល(មិនហាឡាល)។

**ប្រការ ៦.-**

**ការសំឡេះ**

អ្នកសំឡេះតាមបែបហាឡាលត្រូវគោរពគោលការណ៍ ដូចខាងក្រោម៖

១. អ្នកសំឡេះត្រូវតែជាជនមុស្លីម ដែលមានសតិអារម្មណ៍ល្អ ហើយយល់ដឹងយ៉ាងច្បាស់ពីគោលការណ៍វិន័យឥស្លាមជាមូលដ្ឋាន ដែលពាក់ព័ន្ធនឹងការងារសំឡេះសត្វនៅក្នុងសាសនាឥស្លាម
២. អ្នកសំឡេះត្រូវសូត្រថា "ពីសមីលឡា អុលឡោះហ៊ូអឹកពើគរ៍" ( بسم الله ، الله اكبر ) (ភាសាអារ៉ាប់) ភ្លាមៗនៅមុនពេលសំឡេះសត្វនីមួយៗ ត្រូវតម្រង់មុខទៅកាន់ទិសគីបឡាត់ (គឺទិសខាងលិចសម្រាប់កម្ពុជា)
៣. សម្ភារសំឡេះត្រូវមុត ហើយសម្អាតជាមួយទឹកស្អាតមុនពេលសំឡេះ
៤. កាំបិត ឬឧបករណ៍សំឡេះត្រូវតែមុត
៥. អ្នកសំឡេះត្រូវសំឡេះតែមួយដង ដោយគ្មានលើកកាំបិតចេញពីកសត្វ ដើម្បីធានាថាសត្វស្លាប់ភ្លាមៗ និងដើម្បីកាត់បន្ថយការឈឺចាប់
៦. មិនតម្រូវឲ្យដាក់ថ្នាំសណ្ដំឲ្យសន្លប់ ដល់សត្វមុនសំឡេះ លើកលែងក្នុងករណីចាំបាច់ដែលអាចទទួលយកបាន ហើយស្របតាមច្បាប់ឥស្លាម
៧. មិនតម្រូវឲ្យសំឡេះសត្វ ដោយប្រើម៉ាស៊ីនសំឡេះ លើកលែងក្នុងករណីចាំបាច់ ហើយស្របតាមការអនុញ្ញាតរបស់គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា
៨. សត្វដែលអនុញ្ញាតឲ្យសំឡេះត្រូវដាក់នៅកន្លែងដោយឡែកដាច់ពីសត្វដែលមិនអនុញ្ញាត (មិនហាឡាល)
៩. សត្វដែលហាឡាលត្រូវដឹកជញ្ជូន ដាក់ឆ្ងាយពីសត្វដែលគេហាមឃាត់(មិនហាឡាល)
១០. សត្វដែលយកមកសំឡេះ ត្រូវតែជាសត្វដែលហាឡាល
១១. សត្វនោះត្រូវនៅរស់ មានសុខភាពល្អ មុននឹងសំឡេះដែលឯកភាពដោយអាជ្ញាធរមានសមត្ថកិច្ច
១២. សត្វនោះត្រូវរស់នៅបែបធម្មជាតិ គ្មានការធ្វើទារុណកម្មមុនសំឡេះ
១៣. សត្វដែលយកមកសំឡេះ ត្រូវតែជាសត្វដែលមានជីវិត ឬចាត់ទុកថាមានជីវិត នៅពេលសំឡេះ
១៤. សត្វសំឡេះត្រូវផ្ដាច់បំពង់ខ្យល់ បំពង់រំលាយអាហារ សរសៃឈាមទៅចិញ្ចឹមក្បាល និងសរសៃឈាមចូលបេះដូង ដើម្បីឲ្យឆាប់ហូរឈាម នាំដល់ស្លាប់មួយរំពេច
១៥. សត្វត្រូវស្លាប់ដោយការសំឡេះតែប៉ុណ្ណោះ ហើយត្រូវបណ្ដោយសត្វឲ្យដាច់ខ្យល់ដោយឯកឯង
១៦. ចំណុចផ្សេងៗ ត្រូវអនុវត្តតាមគោលការណ៍របស់គណៈដឹកនាំជាន់ខ្ពស់ នៃសាសនាឥស្លាមកម្ពុជា។

**ប្រការ ៧.-**

**ទំនួលខុសត្រូវរបស់ម្ចាស់សត្តឃាតដ្ឋាន**

១. ម្ចាស់សត្តឃាតដ្ឋានត្រូវធានាថា ការអនុវត្តស្តង់ដារហាឡាល ត្រូវបានអនុវត្តន៍នៅក្នុងគ្រប់ដំណើរការរួមទាំងដំណើរការគ្រប់គ្រងធនធានមនុស្ស និងរាល់ព័ត៌មានដែលពាក់ព័ន្ធនឹងច្បាប់ ឥស្លាមត្រូវទាក់ទងដោយផ្ទាល់ ទៅគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា ដើម្បីឲ្យការអនុវត្តបានជោគជ័យ
២. ម្ចាស់សត្តឃាតដ្ឋានត្រូវសហការជាមួយក្រុមឯកទេសផលិតផលហាឡាលកម្ពុជា ដើម្បីពិនិត្យរាល់នីតិវិធីនៃការសំឡេះ
៣. ម្ចាស់សត្តឃាតដ្ឋានត្រូវតែងតាំងទីប្រឹក្សាហាឡាល ដើម្បីពិនិត្យដំណើរការសំឡេះ ក្នុងគោលបំណងផ្ដល់ការប្រឹក្សាយោបល់ និងត្រួតពិនិត្យយ៉ាងល្អិតល្អន់ពីនីតិវិធីនៃការសំឡេះ
៤. ម្ចាស់សត្តឃាតដ្ឋានត្រូវទទួលការបណ្ដុះបណ្ដាលពីដំណើរការសំឡេះសត្វ ពីគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា
៥. ម្ចាស់សត្តឃាតដ្ឋានត្រូវបង្កើត និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធនៃសត្តឃាតដ្ឋានហាឡាល ដែលមានចែងក្នុងគោលការណ៍ណែនាំដូចខាងក្រោមៈ

ក. រៀបចំឲ្យមាននូវបន្ទប់ថ្វាយបង្គំ បន្ទប់អាហារ បន្ទប់ទឹក ទូរដាក់អីវ៉ាន់។ល។ ប្រកបដោយភាពស្អាតល្អ និងអនាម័យ

ខ. សម្ភារត្រូវប្រើក្នុងដំណើរការសំឡេះ ទុកសាច់/ស្បែក ការដឹកជញ្ជូន និងចែកចាយ

គ. ការរៀបចំប្រព័ន្ធបង្ហូរទឹក ឈាម ទុកដាក់លាមកសត្វ ។ល។ ចៀសវាងបង្កភាពស្មោគគ្រោកដែលនាំឲ្យប៉ះពាល់ដល់បរិស្ថាន និងអ្នករស់នៅជុំវិញ។

**ប្រការ ៨**.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៩**.-

នាយកខុទ្ទកាល័យ អគ្គាធិការ អគ្គនាយក ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងពាណិជ្ជកម្ម គណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា ក្រុមឯកទេសផលិតផលហាឡាលកម្ពុជា ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៥រោច ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជា**

**ប្រធានគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា**

**ប៉ាន-សូរស័ក្តិ**

**ចម្លងជូន:**
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យ**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី**
-ខុទ្ទកាល័យសម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី **ស ខេង**
-ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ
-អគ្គនាយកដ្ឋានកាំកុងត្រូល
-គ្រប់រដ្ឋបាលរាជធានី-ខេត្ត
-មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត
-ដូចប្រការ៩ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ